# ត្រូវរក្សាទុកប័ណ្ណ eWIC និងលេខកូដ PIN ឲ្យមានសុវត្ថិភាព

## ការរក្សាទុកប័ណ្ណ eWIC

- ត្រូវរក្សាទុកប័ណ្ណ eWIC ក្នុងទីកន្លែងដែលមានសុវត្ថិភាព ដូចជាទុកក្នុងកាបូបលុយរបស់អ្នក ។
- រក្សាប័ណ្ណ eWIC កុំឲ្យកខ្វក់ កុំទុកចោលហាលថ្ងៃ ហើយត្រូវរក្សាវាទុកឲ្យឆ្ងាយពីមេដែក និងឧបករណ៍អេឡិចត្រូនិក ។

## សុវត្ថិភាពលេខកូដ PIN

- មិនត្រូវប្រាប់លេខកូដ PIN នៃប័ណ្ណរបស់អ្នក ឲ្យនរណាដឹងឡើយ ។
- បើមាននរណាម្នាក់យកប័ណ្ណ eWIC របស់អ្នក ហើយគេដឹងលេខកូដ PIN របស់វា គេអាចលួចប្រើប្រាក់ក្នុងប័ណ្ណនេះបាន ។ ប្រាក់ក្នុងប័ណ្ណដែលត្រូវគេលួចប្រើនោះ នឹងមិនមានការសងត្រឡប់វិញឡើយ ។

## ការដូរកូដ PIN /ប័ណ្ណ eWIC

- បើអ្នកភ្លេចលេខកូដ PIN នៃប័ណ្ណរបស់អ្នក សូមហៅទូរស័ព្ទទៅកាន់ផ្នែកសេវាកម្មអតិថិជន eWIC (eWIC Customer Service) តាមលេខ 1-855-250-8945 ដើម្បីដូរលេខកូដថ្មី ។
- បើអ្នកបាត់ប័ណ្ណ eWIC ត្រូវគេលួច ឬខូចខាត សូមហៅទូរស័ព្ទទៅកាន់ផ្នែកសេវាកម្មអតិថិជន eWIC តាមលេខ 1-855-250-8945 ។
- បើអ្នកចង់ដូរប័ណ្ណ eWIC ថ្មី សូមទៅកាន់គ្លីនិក WIC ប្រចាំមូលដ្ឋានរបស់អ្នក ឬហៅទូរស័ព្ទទៅលេខ 1-800-437-9300 ដើម្បីដូរប័ណ្ណ eWIC ។

## តើនឹងមានអ្វីកើតឡើង បើសិនជាខ្ញុំភ្លេចលេខកូដ PIN ឬបញ្ចូលលេខកូដខុស?

- បើអ្នកបញ្ចូលលេខកូដ PIN ខុស ចំនួនបួនដងជាប់ៗគ្នា ប័ណ្ណ eWIC របស់អ្នក នឹងត្រូវចាក់សោរជាប់រហូតដល់ពាក់កណ្តាលយប់ ។អ្នកអាចដូរលេខកូដ PIN របស់អ្នកដោយការហៅទូរស័ព្ទទៅកាន់សេវាកម្មអតិថិជន eWIC ។ បើអ្នកមិនបានកំណត់លេខកូដ PIN ឡើងវិញទេនោះ ប័ណ្ណ eWIC របស់អ្នក នឹងត្រូវដោះសោរចេញវិញដោយស្វ័យប្រវត្តិ នៅពាក់កណ្តាលយប់ តែទោះជាយ៉ាងណាក៏ដោយ ក៏អ្នកនៅត្រូវដឹងលេខកូដ PIN របស់អ្នកដដែល ដើម្បីអាចប្រើប្រាស់ប័ណ្ណ eWIC បាន ។

# កម្មវិធីទិញទំនិញ WIC Shopper

ស្កេនលេខកូដនេះ សម្រាប់កម្មវិធី WICshopper ។

1. ទាញយកកម្មវិធី WIC Shopper
2. ជ្រើសយករដ្ឋមេន (Maine) ជាអ្នកផ្តល់សេវាកម្ម WIC របស់អ្នក
3. ជាមួយនឹងកម្មវិធីនេះ អ្នកអាច ៖
   - ស្កេនបាកូដ (barcode) ឬបញ្ចូលអក្សរ UPC ដើម្បី រកមើលថាតើអ្នកអាចទិញទំនិញណាបានខ្លះ
   - រាយការណ៍អំពីទំនិញដែលមិនមាននៅក្នុងបញ្ជីស្បៀង ដែលអ្នកជឿថាត្រូវដាក់បញ្ចូល
   - ពិនិត្យមើលបញ្ជីអាហារក្នុងកម្មវិធី (Maine WIC Food)
   - ស្វែងរក រូបមន្តថ្មី សម្រាប់ការប្រើប្រាស់ស្បៀងដែលអនុម័តដោយ WIC
   - ស្វែងរកគន្លឹះទិញស្បៀងក្នុងតម្លៃថោក និងល្បិចក្នុងការប្រើប្រាស់ស្បៀង WIC

*ការប្រើកម្មវិធី WIC Shopper គឺឧបករណ៍របស់អ្នកត្រូវតែភ្ជាប់ជាមួយអ៊ិនធឺណិត (ដោយប្រើទិន្នន័យទូរស័ព្ទចល័ត ឬវ៉ាយហ្វៃ)

**មានសំណួរ? សូមទាក់ទងជាមួយនឹងគ្លីនិក WIC ប្រចាំមូលដ្ឋានរបស់អ្នក ឬចូលទៅកាន់វ៉ិបសៃត៍របស់យើងខ្ញុំតាមអាសយដ្ឋាន www.maine.gov/WIC 1-800-437-9300**

ស្ថាប័ននេះ ជាអ្នកផ្តល់សេវាកម្មដែលមិនមានការរើសអើង ។

# សូមស្វាគមន៍មកកាន់ eWIC ដែលជាវិធីងាយស្រួល និងលឿនក្នុងការទិញទំនិញ!




- ជាមួយនឹង eWIC អត្ថប្រយោជន៍ WIC របស់គ្រួសារអ្នក នឹងត្រូវដាក់បញ្ចូលក្នុងប័ណ្ណ eWIC របស់អ្នក នៅឯការិយាល័យ WIC ។
- បញ្ជីស្បៀងអាហាររបស់អ្នក នឹងបញ្ជូនទៅឲ្យអ្នក ដោយមានបញ្ជាក់អំពីអំឡុងពេលចាប់ផ្តើម និងចប់ ក្នុងការទទួលបានអត្ថប្រយោជន៍នេះ ។
- អ្នកត្រូវប្រើប័ណ្ណ ME eWIC របស់អ្នក ដើម្បីទិញស្បៀង WIC ដែលបានអនុម័ត នៅតាមហាង ME WIC ដែលបានទទួលការអនុញ្ញាតឲ្យលក់ ។

ស្កេនលេខកូដទាំងនេះ ដើម្បីសិក្សាបន្ថែមអំពី eWIC

# ការចាប់ផ្ដើមប្រើប័ណ្ណ

មុនពេលអ្នកអាចប្រើប័ណ្ណ Maine eWIC បាន អ្នកត្រូវជ្រើសរើសលេខកូដសម្គាល់ (PIN) ចំនួន 4 ខ្ទង់

សូមធ្វើតាមការណែនាំទាំងនេះ ៖

- ហៅទូរស័ព្ទទៅកាន់លេខដែលមាននៅខាងខ្នងនៃប័ណ្ណ eWIC របស់អ្នក
- បញ្ចូលលេខប័ណ្ណដែលនៅផ្នែកខាងមុខប័ណ្ណ
- បញ្ចូលថ្ងៃខែឆ្នាំកំណើតរបស់អ្នកក្នុងទ្រង់ទ្រាយ លេខខែ 2 ខ្ទង់ លេខថ្ងៃ 2 ខ្ទង់ និងលេខឆ្នាំ 4 ខ្ទង់
- បញ្ចូលលេខហ្សិបកូដបច្ចុប្បន្ន សម្រាប់ផ្ញើសំបុត្ររបស់អ្នក បញ្ចូលលេខកូដ PIN ចំនួន 4 ខ្ទង់ ដែលអ្នកអាចចងចាំបាន
- បញ្ចូលលេខ PIN 4 ខ្ទង់របស់អ្នកម្ដងទៀត ដើម្បីបញ្ជាក់

ហៅទូរស័ព្ទទៅកាន់ផ្នែកសេវាកម្មអតិថិជន eWIC ដើម្បីឆែកមើលចំនួនប្រាក់ជំនួយរបស់អ្នកដែលនៅសល់ក្នុងប័ណ្ណ ពិនិត្យមើលថាអ្នកបានទិញអ្វីខ្លះ និងព័ត៌មានគណនីរបស់អ្នក ៖

ហៅទូរស័ព្ទទៅកាន់ផ្នែកសេវាកម្មអតិថិជនរបស់ eWIC ដែលបម្រើសេវាកម្ម 24/7 ដោយមិនអស់ប្រាក់ តាមលេខ ៖ 1-855-250-8945

**ពេលមកហាងទិញស្បៀង ត្រូវយកប័ណ្ណ Maine eWIC របស់អ្នកមកជាមួយ ទើបអាចប្រើប្រាក់ជំនួយក្នុងប័ណ្ណនេះបាន**

## គន្លឹះសំខាន់ៗ

- ខណ្ឌប័ណ្ណ (Coupons) និង "BOGO" ដែលអ្នកទទួលបាន អាចយកមកប្រើដើម្បីទិញទំនិញដែលបានទទួលការអនុញ្ញាតដោយ WIC ។ សូមកុំភ្លេចយកវាតាមខ្លួន នៅពេលស្វែនទំនិញរបស់អ្នកដែលបានអនុម័តិដោយ WIC ដើម្បីអាចប្រើវាបាន ។
- ហាងទំនិញខ្លះមានផ្ដល់ជូន 'ប្រាក់រង្វាន់' ប្រចាំត្រីមាស ។ដើម្បីធានាបានថា ប្រាក់ជំនួយក្នុងចំនួននេះប្រើបានត្រឹមត្រូវ សូមបំបែកទំនិញ WIC និងរបស់ដែលអ្នកទិញជាប្រចាំ ។ការធ្វើបែបនេះ គឺដើម្បីអាចធានាបានថា ប្រាក់រង្វាន់របស់អ្នកអាចប្រើបាន ដើម្បីទិញទំនិញដែលមិនមែនជាស្បៀង WIC ។

# យល់ដឹងអំពីអត្ថប្រយោជន៍របស់អ្នក

អត្ថប្រយោជន៍របស់អ្នក អាចយកមកប្រើបានតាមកាលបរិច្ឆេទចាប់ផ្ដើម នៅម៉ោង 12:00 យប់ ហើយបញ្ចប់ទៅវិញ តាមកាលបរិច្ឆេទផុតកំណត់ជំនួយ នៅម៉ោង 11:59 នាទីយប់ ។

ប្រាក់ជំនួយដែលនៅមិនទាន់បានចំណាយ មិនអាចបន្តយកទៅប្រើក្នុងថិរវេលាផ្ដល់ជំនួយខាងមុខបានឡើយ ។

**អ្នកអាចប្រើប័ណ្ណនេះទិញទំនិញបានគ្រប់ទីកន្លែងដែល Maine eWIC ទទួលយក**

## របៀបទិញស្បៀងក្នុងបញ្ជី WIC

- ត្រូវដឹងអំពីចំនួនប្រាក់ជំនួយសម្រាប់ទិញ WIC នៅសល់ក្នុងប័ណ្ណ មុនពេលទិញទំនិញ ។
- ជ្រើសរើសស្បៀង WIC របស់អ្នក ដោយប្រើចំនួនប្រាក់ជំនួយរបស់គ្រួសារអ្នកដែលនៅសល់ក្នុងប័ណ្ណ និងជ្រើសរើសទិញស្បៀងទៅតាមអ្វីដែលមានក្នុងបញ្ជីស្បៀង ដែល WIC អនុម័តិ ។
- បើសិនជាអ្នកត្រូវបញ្ជាទិញ WIC ទំនិញមួយមុខៗច្រើនជាង 50 UPCs អ្នកត្រូវតែបំបែកទំនិញ WIC ពីការទិញផ្សេងទៀត ។
- អ្នកគិតប្រាក់ ស្កែនស្បៀង WIC ដែលអ្នកទិញ ។
- ជានិច្ចកាល សូមប្រើប័ណ្ណ eWIC របស់អ្នក ជាជម្រើសដំបូងនៃការបង់ប្រាក់ ។
- ឆូតប័ណ្ណ eWIC របស់អ្នក នៅពេលម៉ាស៊ីន PIN ប្រាប់ឲ្យឆូត រួចបញ្ចូលលេខកូដ PIN ចំនួនបួនខ្ទង់របស់អ្នក
- ពិនិត្យមើលវិក្ក័យប័ត្របញ្ជាក់ការទិញទំនិញក្រោយឆូតប័ណ្ណរួចរាល់ ដែលអ្នកគិតលុយចេញឲ្យអ្នក ។ត្រូវប្រាកដថា ស្បៀង WIC ដែលអ្នកគិតថាបានបង់ប្រាក់រួចរាល់ ដោយប័ណ្ណ eWIC មានសរសេរនៅក្នុងវិក្ក័យប័ត្របង់ប្រាក់ ។
- ចុចលើពាក្យ "Yes" ដើម្បីទទួលយកប្រតិបត្តិការ ឬចុចលើពាក្យ "No" បើស្បៀងដែលអ្នកគិតថាអាចបង់តាមប័ណ្ណ eWIC មិនមាននៅក្នុងវិក្ក័យប័ត្រ ។ ស្បៀងដែលមិនអាចបង់តាមរយៈប័ណ្ណ eWIC អាចត្រូវលុបចេញពីការបញ្ជាទិញរបស់អ្នក ឬក៏អ្នកអាចបង់ថ្លៃរបស់វាដោយវិធីផ្សេងទៀត (ដូចជា ការបង់តាមរយៈជំនួយ SNAP ឥណពន្ធ ឥណទាន ឬសាច់ប្រាក់សុទ្ធ)
- យកប័ណ្ណ និងវិក្ក័យប័ត្រពីអ្នកគិតលុយ ។
- រក្សាវិក្ក័យប័ត្រចុងក្រោយរបស់អ្នក - នៅក្នុងវិក្ក័យប័ត្រនេះ មានបង្ហាញអំពីចំនួនទឹកប្រាក់របស់អ្នកនៅសល់ក្នុងខែនោះ ហើយវាក៏ជាឯកសារមួយសម្រាប់ប្រគល់ជូនការិយាល័យ WIC របស់អ្នកផងដែរ បើសិនជាមានបញ្ហាអ្វីមួយកើតឡើង ។

# របៀបមើលវិក្ក័យប័ត្រ

វិក្ក័យប័ត្រចុះសាច់ប្រាក់របស់អ្នក នឹងមានសរសេររាយឈ្មោះស្បៀង WIC ដែលអ្នកបានទិញ ក៏ដូចជាស្បៀងដែលនៅសល់ ព្រមទាំងថ្ងៃផុតកំណត់ជំនួយរបស់អ្នក ។ នេះជាឧទាហរណ៍ ៖


ABC Market
1 Main Street
Anywhere, USA 12345
Ph: (123) 456-7890
Store ID: WICW006

Term ID: WIC006001
Clerk ID: 999 10:10:01am

Card Num: XXXXXXXXXXXX5678 Auth #: 123499
WIC Merchant ID: XXXXXXX Seq #: 034
Settlement Date: 03/01

**WIC Purchase**

| Qty | Units | Description | Price |
|---|---|---|---|
| 18.00 | oz | Cheerios 18 oz. | 4.99 |
| 2.50 | $$$ | Fruits & Veg | 2.50 |

TOTAL ITEMS SOLD = 2
$2.50 - Fruits & Veggies

PURCHASE SUBTOTAL 7.49
DISCOUNT APPLIED 0.00

APPROVED PURCHASE TOTAL 7.49

BALANCE DUE: 0.00

BENEFITS EXPIRE ON 3/31/2018

| Qty | Units | Description |
|---|---|---|
| 1.00 | pkg | 16oz Pkg Cheese |
| 1.00 | doz | Dozen Large Eggs |
| 18.00 | oz | Ounces Cereal |
| 2.00 | pkg | 18oz PnutBtr/DryBeans |
| 1.00 | pkg | 16oz Bread/Whole Grain |
| 3.00 | gal | Gallon 1% Fat Free Milk |
| 1.00 | qt | Qts 1% Fat Free Milk |
| 2.00 | cont | 64oz Bottle 100% Juice |
| 5.50 | $$$ | Fruits & Veg |

****CARDHOLDER COPY****
****PLEASE SAVE THIS RECEIPT****

eWIC